**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការខេត្តព្រះសីហនុ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣០២ ចុះថ្ងៃទី ២៦

ខែ ធ្នូ ឆ្នាំ ២០០៤

សាលក្រម

លេខៈ ១០ ចុះថ្ងៃទី ០៤

ខែ កុម្ភៈ ឆ្នាំ ២០០៥

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការខេត្តព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅនេះ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញាស្តីទីអមតុលាការក្រុងព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងព្រះសីហនុ

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣០២ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទឈ្មោះ :

-ស ឧ ឈ្មោះហៅក្រៅ ទី ឧ ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ ១ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ទីលំនៅសព្វថ្ងៃក្រុម៣ ភូមិ១ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ី ជាងសំណង់ ឪពុកឈ្មោះ ស ឧ (ស) ម្តាយឈ្មោះ ព ឧ (រ) ហៅយាយវែង ប្រពន្ធគ្មាន កូនគ្មាន ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ លេខ ២០៧ ជយខ.០៤ ។

-ឈ្មោះ ស ច ជាតំណាងអោយក្រុមហ៊ុនភាពីម៉ិច និង ដើមបណ្តឹងបានឆ្លើយថា នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៤ វេលាម៉ោង ៤ល្ងាច ខ្លួនបានទៅដល់ក្រុមហ៊ុនក៏ឃើញចោរម្នាក់ កំពុងតែធ្វើសកម្មភាពកាត់ខ្សែរភ្លើង ប្រមូលដាក់ក្នុងបាវ ខ្លួនក៏ឃាត់វាហើយឆែកឆេរមើលក្នុងបាវ ឃើញខ្សែភ្លើង កាំបិតផ្គាក់ ភ្លើងហ្វាចំនួនមួយ កូនកាំបិតតូចមួយ ហើយរបស់ទាំងអស់នេះជារបស់ក្រុមហ៊ុន សំភារៈទាំងអស់នេះសមត្ថកិច្ចក៏យកទៅរក្សាទុកនៅកន្លែងសមត្ថកិច្ច ខ្លួនមិនទាន់បានទទួលពីសមត្ថកិច្ចនៅឡើយ ។ ក្នុងរឿងនេះខ្លួនសុំអោយតុលាការផ្តន្ទាទោសតាមច្បាប់ចំពោះជនល្មើស រីឯសំណងជំងឺចិត្ត ខ្លួនមិនទាមទារឡើយ និង សំភារៈដែលរក្សាទុកនៅសមត្ថកិច្ច ខ្លួនសុំអោយតុលាការសំរេចអោយក្រុមហ៊ុនវិញ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ស ឧ ហៅ ទី ឧ ពីបទចោរកម្ម ប្រព្រឹត្តនៅសង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ

សាលក្រមនេះបានចូលជាស្ថាពរហើយ ។
ក្រុងព្រះសីហនុ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៥
ក្រឡាបញ្ជី
[redacted]

កាលពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៤ ហេតុនេះសុំឱ្យចៅក្រមជំនុំជំរះវិនិច្ឆ័យសេចក្តីតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ដោយក្តីអនុគ្រោះ ។

-ឈ្មោះ ស ឧ ជាជនជាប់ចោទបានឆ្លើយសំដីចុងក្រោយបង្ហស់ថា ខ្លួនសុំអោយតុលាការជួយបន្ធូរបន្ថយទោស អោយខ្លួនផង ព្រោះខ្លួនមានជីវភាពក្រីក្រ ហើយសន្យាថា ឈប់ប្រព្រឹត្តអំពើនេះទៀតហើយ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹង

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

## តុលាការក្រុងព្រះសីហនុ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-ជនជាប់ចោទបានឆ្លើយថា ដោយសារជីវភាពក្រីក្រ ទើបខ្លួនដាច់ចិត្តចូលលួចយកសំភារៈមួយចំនួន ដែល ម្ចាស់មិនសូវនៅក្នុងក្រុមហ៊ុន ។

-នៅពេលលួចនោះបានប្រមូលខ្សែភ្លើងធ្លាក់នៅដីយកកាំបិតផ្គាក់ កាំបិតតូច អំពូលភ្លើងហ្វា និង សាកាដូ ដាក់ក្នុងបាវ បំរុងយកចេញម្ចាស់ក៏មកទាន់ប្តឹងសមត្ថកិច្ច ហើយចាប់ខ្លួនជនល្មើសតែម្តង ។

-សំភារៈដែលជនល្មើសលួចបំរុងយកទៅនេះ បានរក្សានៅកន្លែងសមត្ថកិច្ចនគរបាលក្រុងព្រះសីហនុមិនបាន ប្រគល់អោយតំណាងអយ្យការដើម្បីរក្សាទុកទេ តែសំភារៈនេះតំណាងម្ចាស់ក្រុមហ៊ុនបានស្នើសុំ ដើម្បីយកទៅប្រើ ប្រាសវិញ បណ្តើងសុំមានលក្ខណៈសមស្របតាមច្បាប់ ។

-ឈ្មោះ ស ឧ ជាអនីតិជន កំព្រាឪពុក ការគិតពិចារណាមិនបានវែងឆ្ងាយ និង ដោយសារជីវភាព ទើបខ្លួន ហ៊ានប្រព្រឹត្តអំពើបែបនេះ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ស ឧ** ហៅ **ខ្មី ឧ** ពីបទចោរកម្ម ប្រព្រឹត្តនៅសង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោស តាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ
## ស ំ រ េ ច :

**ផ្តន្ទាទោស :**

១-ឈ្មោះ ស ឧ ហៅ ខ្មី ឧ ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៦ខែ ( ប្រាំមួយ ខែ) ពីបទចោរកម្ម ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា ៤៣ មាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-វត្ថុតាងរួមមានខ្សែភ្លើង ៣០គីឡូក្រាម កាំបិតផ្គាក់ចំនួន ០២ (ពីរ) កាំបិតតូចដងពណ៌ខ្មៅចំនួន ០១ (មួយ) អំពូលភ្លើងហ្វាចំនួន ០១ (មួយ) ដែលមានកំណត់ហេតុដកហូត ហើយរក្សាទុកនៅស្នងការដ្ឋាននគរបាលក្រុងព្រះសីហនុ នោះត្រូវប្រគល់អោយឈ្មោះ ស ឃ ជាតំណាងអោយក្រុមហ៊ុនភាពីម៉ិចប្រើប្រាស់វិញ ចាប់តាំងពីថ្ងៃនេះតទៅ ។

សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទ ដើមបណ្ដឹង បើកផ្លូវប្ដឹងឧទ្ធរណ៍ ក្នុងកំឡុងច្បាប់ ។

ក្រឡាបញ្ជី
[redacted]

ចៅក្រមជំនុំជំរះ
[redacted]